USAID
FROM THE AMERICAN PEOPLE

# Action Alliance for Preventing Sexual Misconduct (AAPSM) Training for Implementing Partner Staff

June 26, 2019







USAID
FROM THE AMERICAN PEOPLE

# វគ្គបណ្តុះបណ្តាល ស្តីពី ចលនារួបរួមដើម្បីទប់ស្កាត់អំពើមិនគប្បី ខាងផ្លូវភេទ ឬ AAPSM ដល់បុគ្គលិកអង្គការដៃគូរបស់ USAID

ខែមិថុនា 26 ឆ្នាំ 2019







# Background សាវតា

- **March 2018:** USAID Administrator Mark Green established the Action Alliance for Preventing Sexual Misconduct (AAPSM), an intra-Agency working group charged with a renewed initiative to address and prevent sexual misconduct in all its forms.
- *មិនា ២០១៨៖ នាយករបស់អង្គការ USAID លោក Mark Green បានបង្កើតចលនាមួយឡើងដើម្បីទប់ស្កាត់អំពើមិនគប្បីខាងផ្នែកផ្លូវភេទ ឬ AAPSM ដែលជាក្រុមការងារអន្តរភ្នាក់ងារ ទទួលបន្ទុកអនុវត្តកិច្ចការដើម្បីដោះស្រាយ និងទប់ស្កាត់អំពើមិនគប្បីខាងផ្លូវភេទ មិនថាក្នុងទម្រង់ណាមួយឡើយ។*

- **April 2018:** USAID/Cambodia convened a meeting with implementing partners (IPs) to discuss the issues covered under AAPSM.
- *មេសា ២០១៨៖ អង្គការ USAID ប្រចាំប្រទេសកម្ពុជា បានជួបប្រជុំជាមួយដៃគូអនុវត្ត (IP) ដើម្បីពិភាក្សាជុំវិញបញ្ហានានាទាក់ទងនឹង AAPSM។*

# Background សាវតា

- **October 2018:** Mission Directors and other senior managers were tasked with promoting a culture change around sexual misconduct within their teams by modeling respect, inclusion, and accountability.
- តុលា ២០១៨៖ នាយក-នាយិកាបេសកកម្មនានា រួមជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ដទៃទៀត ត្រូវបានចាត់តាំងឲ្យសម្រេចកិច្ចការទាក់ទងនឹងការលើកកំពស់ការផ្លាស់ប្តូរវប្បធម៌អំពី អំពើមិនគប្បីខាងផ្នែកផ្លូវភេទ ជាមួយនឹងក្រុមការងាររបស់ខ្លួន ដោយយកជាធំនូវ ការគោរព បរិយាប័ន្ន និងការទទួលខុសត្រូវ។

- **Core Message:** USAID has zero tolerance for sexual misconduct.
- សារសំខាន់៖ USAID មិនអត់អោនជាដាច់ខាតចំពោះអំពើមិនគប្បីខាងផ្នែកផ្លូវភេទ។

# Zero Tolerance មិនមានការអត់អោនជាដាច់ខាត

- USAID prohibits sexual misconduct of any kind, including harassment, exploitation, or abuse, among USAID staff or our implementing partners.
- *USAID ហាមអំពើមិនគប្បីខាងផ្លូវភេទ ក្នុងគ្រប់រូបភាពទាំងអស់ រួមមាន ការបៀតបៀន ការកេងប្រវ័ញ្ច ឬរំលោភបំពាន មិនថាប្រព្រឹត្តិដោយបុគ្គលិក USAID ផ្ទាល់ ឬបុគ្គលិកដៃគូអនុវត្តគម្រោងឡើយ។*

- Sexual misconduct is counter to our Agency’s core values.
- *អំពើមិនគប្បីខាងផ្លូវភេទ គឺផ្ទុយស្រឡះពីគុណតម្លៃដ៏សំខាន់របស់ភ្នាក់ងារ។*

# Zero Tolerance មិនមានការអត់អោនជាដាច់ខាត

- Sexual misconduct fundamentally strikes at the very foundation of international development by causing intolerable harm to its victims, threatening our mission, and undermining the credibility of the entire aid sector.
- *អំពើមិនគប្បីខាងផ្លូវភេទ បង្កឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើមូលដ្ឋាននៃការអភិវឌ្ឍន៍អន្តរជាតិ ដោយសារការណ៍នេះនឹងបង្កឲ្យមានភាពអត់អោនទៅលើការបំពារបំពានដែលកើតឡើងចំពោះជនរងគ្រោះ គំរាមកំហែងដល់បេសកកម្មរបស់យើង ហើយថែមទាំងធ្វើឲ្យអាប់អោនដល់កិត្តិនាមនវិស័យផ្តល់ហិរញ្ញប្បទានទាំងមូលទៀតផង។*

- USAID will take necessary and appropriate steps to prevent and address sexual misconduct within our workforce and programs, while also accounting for survivor needs.
- *USAID នឹងចាត់វិធានការចាំបាច់ និងសាកសមដើម្បីទប់ស្កាត់ និងដោះស្រាយអំពើមិនគប្បីខាងផ្លូវភេទដែលកើតមាននៅក្នុងកន្លែងធ្វើការ និងគម្រោងរបស់យើង ខណៈពេលដែលទទួលខុសត្រូវលើតម្រូវការនានារបស់ជនរងគ្រោះ។*

# Exercise: Terminology
# លំហាត់៖ វាក្យស័ព្ទ

| **Term ពាក្យ** | **Definition និយមន័យ** |
| --- | --- |
| Sexual Misconduct អំពើមិនគប្បីខាងផ្លូវភេទ | Umbrella term that encompasses ***any*** inappropriate behavior of a sexual nature or that is sex-based, including sexual abuse, sexual assault, sexual exploitation, sexual harassment, intimate partner violence, stalking, voyeurism, and any other such conduct that is non-consensual or has the purpose or effect of threatening, intimidating, denigrating, or coercing a person.<br>ជាពាក្យដែលក្តោបទៅលើរាល់ឥរិយាបថទាំងឡាយណាដែលមិនគួរសម ហើយទាក់ទងនឹងផ្លូវភេទ ឬដោយសារតែរឿងភេទ រួមមានការរំលោភបំពានផ្លូវភេទ ការបំពារបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ ការបៀតបៀនផ្លូវភេទ អំពើហិង្សាលើដៃគូរួមស្នេហា ការលួចលបមើល ការលួចមើលគេរួមភេទ និងអំពើមិនគប្បីនានាទៀតដែលមិនមានការយល់ព្រម ឬក្នុងគោលបំណង ឬចង់បង្កឲ្យមានការគំរាមកំហែង បំភ័យ បន្ទាបបន្ថោក ឬចេតនាលួងលោមនរណាម្នាក់។ |

| Term ពាក្យ | Definition និយមន័យ |
| --- | --- |
| Sexual Harassment ការបៀតបៀនផ្លូវភេទ | Misconduct of a sexual nature or about a person’s sex that is so frequent or severe as to create a hostile or offensive work environment or that results in an adverse employment decision, such as the victim being fired or demoted. It can include verbal or physical harassment of a sexual nature, as well as offensive remarks related to a person’s sex.<br>ជាអំពើមិនគប្បីទាក់ទងនឹងផ្លូវភេទ ឬអំពីភេទរបស់ជនណាមួយដែលកើតឡើងជាញឹកញាប់ ឬក្នុងកម្រិតធ្ងន់ធ្ងរ ដែលនេះអាចបង្កឲ្យមានបរិយាកាសមិនល្អនៅក្នុងការិយាល័យ ឬធ្វើឲ្យប៉ះពាល់ផ្លូវចិត្តបុគ្គលិក ឬដែលបណ្តាលឲ្យប៉ះពាល់ដល់លទ្ធផលការងាររបស់គេ ដូចជា ជនរងគ្រោះត្រូវបញ្ឈប់ពីការងារ ឬត្រូវបានទម្លាក់ពីតំណែង។ អំពើបៀតបៀនទាំងអស់អាចកើតមានតាមរយៈ ពាក្យសម្តី ឬកាយវិការ ដែលទាក់ទងនឹងផ្លូវភេទ ឬពាក្យពេចន៍មិនគប្បីអំពីភេទរបស់នរណាម្នាក់។ |

| **Term** ពាក្យ | **Definition** និយមន័យ |
| --- | --- |
| Sexual Exploitation ការកេងប្រវ័ញ្ចផ្លូវភេទ | Any actual or attempted abuse by aid workers of a position of vulnerability, differential power, or trust, for sexual purposes, including profiting monetarily, socially, or politically from the sexual exploitation of another. ការរំលោភបំពានទាំងឡាយណា មិនថាកើតឡើងជាក់ស្តែង ឬគ្រាន់តែប៉ុនប៉ង ដែលបង្កដោយបុគ្គលិកជំនួយនៃលក្ខខណ្ឌ ងាយរងគ្រោះ មានអំណាចខុសគ្នា ឬដោយសារមានទំនុកចិត្ត ក្នុងគោលបំណងផ្លូវភេទ ដោយទទួលផលចំណេញផ្នែកហិរញ្ញវត្ថុ ផ្នែកសង្គម ឬផ្នែកនយោបាយ ពីការកេងប្រវ័ញ្ចផ្លូវភេទពីជនណាម្នាក់។ |
| Sexual Abuse ការ រំលោភបំពានផ្លូវភេទ | Any actual or threatened physical intrusion of a sexual nature, whether by force or under unequal or coercive conditions. រាល់ការបំពារបំពានរាងកាយទាំងឡាយណា មិនថាកើតឡើងជាក់ស្តែង ឬតាមរយៈការគំរាមកំហែងដែលពាក់ព័ន្ធនឹងផ្លូវភេទ មិនថាដោយការបង្ខំ ឬក្រោមលក្ខខណ្ឌដែលគ្មានភាពស្មើគ្នា ឬដោយការលួងលោម។ |

The misconduct ***does not*** need to rise to the level of civil or criminal illegality to warrant corrective or disciplinary action.

រាល់អំពើមិនគប្បី មិនចាំបាច់ ទាល់តែធំដល់កម្រិតខុសច្បាប់ខាងរដ្ឋប្បវេណី ឬឧក្រិដ្ឋនោះទេ សុទ្ធតែត្រូវឲ្យមានវិធានការកែតម្រូវ ឬពិន័យ។

# Preventing Sexual Exploitation and Abuse (1)
# *ទប់ស្កាត់ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (1)*

USAID prohibits all of our contractors, sub-contractors, grantees, and sub-grantees (including their employees), during the period of performance of their contracts or awards, and regardless of award amount, from engaging in trafficking in persons, procuring commercial sex acts, and using forced labor.

*USAID ហាមរាល់ស្ថាប័នជាប់កិច្ចសន្យា អនុកិច្ចសន្យា ដៃគូអនុវត្តគម្រោង និងអនុដៃគូអនុវត្តគម្រោង (រួមទាំងបុគ្គលិក) ក្នុងអំឡុងពេលបំពេញការងារទៅតាមកិច្ចសន្យា ឬគម្រោងរបស់ពួកគេ មិនថាទឹកប្រាក់ចំនួនប៉ុន្មាន មិនឲ្យជាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស ទិញសេវាផ្លូវភេទ និងការបង្ខំកម្លាំងពលកម្ម។*

# Preventing Sexual Exploitation and Abuse (2)
# *ទប់ស្កាត់ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (2)*

For awards with services performed overseas greater than $500,000, the prime partner must annually certify to its USAID Contracting or Agreement Officer that it has a compliance plan in place to prevent prohibited trafficking-related activities, including procuring commercial sex.

*ចំពោះគម្រោងដែលត្រូវបំពេញការងារនៅក្រៅប្រទេស ហើយមានតម្លៃ
លើសពី 500,000 (៥សែន) ដុល្លារអាមេរិក ដៃគូជាប់កុងត្រា ត្រូវបញ្ជាក់
ជារៀងរាល់ឆ្នាំមកកាន់មន្ត្រី USAID ទទួលបន្ទុកខាងកិច្ចសន្យា ឬកិច្ច
ព្រមព្រៀង ថាស្ថាប័នរបស់ពួកគេមានគម្រោងក្នុងការទប់ស្កាត់សកម្ម
ភាពទាំងឡាយណាទាក់ទងនឹងការជួញដូរមនុស្ស បូករួមទាំងការទិញ
សេវាផ្លូវភេទផងដែរ។*

# Preventing Sexual Exploitation and Abuse (3)
# ទប់ស្កាត់ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (3)

USAID also includes additional protections in grants and contracts to promote the safeguarding of children and youth under the age of 18, and to protect them against abuse, exploitation, and neglect in the implementation of USAID-funded programs.

USAID ក៏បញ្ចូលបន្ថែមផងដែរនូវបញ្ញត្តិការពារទាំងក្នុងកិច្ចព្រមព្រៀងជំនួយ និងកិច្ចសន្យា ដើម្បីលើកកម្ពស់ការគាំពារកុមារ និងយុវជនដែលមានវ័យក្រោម១៨ឆ្នាំ ហើយដើម្បីការពារពួកគេពីការរំលោភបំពាន ការកេងប្រវ័ញ្ច និងការមិនយកចិត្តទុកដាក់ នៅពេលអនុវត្តកម្មវិធីដែលទទួលជំនួយពី USAID។

# Partner Codes of Conduct
# ច្បាប់អនុវត្តសម្រាប់ដៃគូ

- Codes of conduct for all implementing partner employees ***must meet*** internationally recognized standards outlined by the Inter-Agency Standing Committee (IASC) Protection from Sexual Exploitation and Abuse Task Force.
- *ច្បាប់អនុវត្តសម្រាប់បុគ្គលិកដៃគូអនុវត្តកម្មវិធីទាំងអស់ ត្រូវសមស្របទៅនឹងបទដ្ឋានដែលទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ដូចដែលមានចែងដោយក្រុមការងារនៃគណៈកម្មាធិការអចិន្ត្រៃយ៍អន្តរភ្នាក់ងារ (IASC) ស្តីពីការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ*

- Implementing partners are ***required*** to consult with the Agreement Officer, or Contracting Officer, and the Mission Director when an employee's conduct violates IASC standards.
- *ដៃគូអនុវត្តកម្មវិធីទាំងអស់ត្រូវពិភាក្សាជាមួយមន្ត្រីកិច្ចព្រមព្រៀង ឬមន្ត្រីកិច្ចសន្យា និងនាយក-នាយិកាបេសកកម្មនៅពេលដែលបុគ្គលិកណាម្នាក់បំពានច្បាប់អនុវត្តដែលមានលក្ខណៈបទដ្ឋាន IASC នេះ។*

# Partner Codes of Conduct
# ច្បាប់អនុវត្តសម្រាប់ដៃគូ

- Implementing partners are ***required*** to propose an appropriate course of action for that employee.
- *ដៃគូអនុវត្តកម្មវិធី ត្រូវស្នើរវិធានការដែលសាកសមសម្រាប់ដោះស្រាយជាមួយបុគ្គលិករូបនោះ។*

- U.S. Ambassador is empowered to require an IP to remove problem employees from USAID-funded awards, and if the employee is a U.S. citizen, to direct the removal of that individual from the country.
- *អគ្គរដ្ឋទូតអាមេរិក មានអំណាចក្នុងការតម្រូវឲ្យដៃគូអនុវត្តកម្មវិធីបញ្ឈប់បុគ្គលិកពីកម្មវិធីដែលទទួលជំនួយពី USAID ហើយបើបុគ្គលិកនោះជាជនជាតិអាមេរិក ត្រូវបញ្ជារឲ្យបញ្ជូនជននោះចេញពីប្រទេសកម្ពុជា។*

# Reporting Requirements
# តម្រូវការក្នុងការរាយការណ៍

- USAID strongly encourages contractors and grantees to notify the Office of USAID's Inspector General (OIG) immediately of suspected allegations of sexual exploitation and abuse, and to cooperate in any audits, investigations, or corrective actions.
- *USAID លើកទឹកចិត្តខ្លួនស់ឲ្យដៃគូអនុវត្តកម្មវិធី និងកិច្ចសន្យា ផ្តល់ដំណើងដល់អគ្គនាយកដ្ឋានត្រួតពិនិត្យរបស់ USAID (OIG) ភ្លាមៗក្រោយមានការសង្ស័យទៅលើការចោទប្រកាន់ថាមានករណីកេងប្រវ័ញ្ច ឬការរំលោភបំពានផ្លូវភេទ ហើយសហការក្នុងករណីមានការធ្វើសវនកម្ម ការស៊ើបអង្កេត ឬសកម្មភាពកែតម្រូវណាមួយ។*

- To contact the OIG, please visit https://oig.usaid.gov , or call 1-800-230-6539.
- *ដើម្បីទាក់ទង OIG សូមចូលទៅកាន់* **https://oig.usaid.gov** *ឬទូរស័ព្ទទៅលេខ* 1-800-230-6539

# Resources ឯកសារពាក់ព័ន្ធនានា

- The AAPSM Website: www.usaid.gov/PreventingSexualMisconduct
  - Features fact sheets, flowcharts, and information on USAID’s policies and processes, which are equally helpful to USAID’s staff and implementing partners.
- វិបសាយ AAPSM៖ www.usaid.gov/PreventingSexualMisconduct
  - មានព័ត៌មានសង្ខេបៗ រូបភាព និងព័ត៌មានដទៃទៀតដែលទាក់ទងនឹង គោលនយោបាយ និងដំណើរការរបស់ USAID ដែលអាចផ្តល់ជាជំនួយ ដល់បុគ្គលិក USAID និងដៃគូអនុវត្តគម្រោង។

- IASC Six Core Principles Relating to Sexual Exploitation and Abuse (link)
- គោលការណ៍ចំបងទាំង៦ របស់ IASC ទាក់ទងនឹងការកេងប្រវ័ញ្ច និង ការរំលោភបំពានផ្លូវភេទ (តំណភ្ជាប់)

# Resources ឯកសារពាក់ព័ន្ធនានា

- USAID is developing two, new comprehensive policies targeted for release in the coming weeks.
- *USAID* កំពុងបង្កើតគោលនយោបាយថ្មីចំនួន២ ដែលគ្រោងនឹងដាក់ឲ្យអនុវត្តក្នុងពេលឆាប់ៗនេះ។
  - New Chapter in the Agency's operational policy, the Automated Directives System (ADS), related to internal sexual misconduct and harassment. This policy will lay out expectations for USAID staff, and guide the Agency's response in cases of internal sexual misconduct.
  - ជំពូកថ្មីនៃគោលនយោបាយអនុវត្តរបស់ភ្នាក់ងារ ដែលមានឈ្មោះថា *ADS* ទាក់ទងនឹងអំពើមិនគប្បី និងការបៀតបៀនខាងផ្លូវភេទ សម្រាប់ប្រើប្រាស់ក្នុងភ្នាក់ងារផ្ទាល់។ គោលការណ៍នេះនឹងរៀបរាប់អំពីការរំពឹងទុកដែលតម្រូវឲ្យបុគ្គលិក *USAID* ត្រូវគោរពតាម និងជួយតម្រង់ទិសការឆ្លើយតបរបស់ភ្នាក់ងារ ក្នុងករណីដែលមានអំពើមិនគប្បីខាងផ្លូវភេទកើតឡើង។

# Resources ឯកសារពាក់ព័ន្ធនានា

- Policy on Protection from Preventing Sexual Exploitation and Abuse (PSEA) that will clarify roles, responsibilities, and processes for protecting USAID's beneficiaries.
- គោលនយោបាយស្តីពីការការពារ ការទប់ស្កាត់ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ (PSEA) ដែលនឹងរៀបរាប់អំពីតួនាទី ការទទួលខុសត្រូវ និងដំណើរការដើម្បីការពារអ្នកទទួលផលរបស់ USAID។

USAID
FROM THE AMERICAN PEOPLE

# Questions & Discussion
# សំណួរ និងការពិភាក្សា





